ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុសិក្ខាសាលា
# ផ្សព្វផ្សាយឯកសារគោល នៃផែនការសកម្មភាពជាតិ
# ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧-២០១៨
# ក្រសួងមហាផ្ទៃ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែសីហា ថ្ងៃទីប្រាំបួន វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅទីស្តីការក្រសួងមហាផ្ទៃ មានបើកសិក្ខាសាលាផ្សព្វផ្សាយឯកសារគោល នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី** ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយករង លោក លោកស្រី ប្រធាន អនុប្រធាននាយកដ្ឋាន នៃក្រសួង ស្ថាប័ន លោក លោកស្រី មកពីតាមបណ្តារាជធានី-ខេត្ត ព្រមទាំងអង្គការដៃគូពាក់ព័ន្ធមួយចំនួនផងដែរ សរុបចំនួន ១៨៩រូប ស្រី៨៩រូប។

ជាកិច្ចចាប់ផ្តើម នៃអង្គសិក្ខាសាលា លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានឡើងមានមតិស្វាគមន៍ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ជាប្រធានអង្គសិក្ខាសាលា និងឯកឧត្តម លោកជំទាវ លោក លោកស្រី ព្រមទាំងភ្ញៀវជាតិ អន្តរជាតិទាំងអស់ដែលមានវត្តមាននាពេលនេះ ហើយបន្ទាប់មក លោកជំទាវ បានប្រកាសបើកអង្គសិក្ខាសាលាជាផ្លូវការក្នុងកម្មវិធី។

**លោក ជុំ ផល្លី តំណាងអង្គការ** WINROCK International ឡើងធ្វើបទបង្ហាញពីរបាយការណ៍ពាក់កណ្តាលអាណត្តិ នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់គណៈកម្មធិការជាតិ គ.ជ.ប.ជ ដែលបានបញ្ជាក់ពីៈ

- លទ្ធផលការងារ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- អំពីចំណុចខ្លាំង និងចំណុចខ្សោយ
- ការផ្តល់អនុសាសន៍ និងយុទ្ធសាស្ត្របន្ត

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានឡើងធ្វើបទបង្ហាញ អំពីគោលការ នៃផែនការសកម្មភាពថ្នាក់ជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តឆ្នាំ២០១៧-២០១៨ ជូនសម្តេចប្រធាន និងសមាជិកអង្គប្រជុំ ដោយសង្ខេប។

បន្ទាប់ពី លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ ធ្វើបទបង្ហាញរួចមក **សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី** បានមានប្រសាសន៍ទាក់ទងនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជូនសមាជិក នៃអង្គប្រជុំ។ សម្តេច មានប្រសាសន៍សង្កត់ធ្ងន់ទៅលើបញ្ហាចំនួនបីចំណុចដែលត្រូវរួមគ្នាអនុវត្តក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សៈ

១.អំពីបញ្ហាបិទច្រករបៀងតាមបណ្ដាព្រំដែន ជាពិសេសតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រសួងមហាផ្ទៃ ក៏ដូចជាអគ្គស្នងការនគរបាលជាតិ ធ្លាប់បានណែនាំអំពីការបិទច្រករបៀងទាំងអស់តាមព្រំដែនកម្ពុជា ជាមួយប្រទេសជាប់ព្រំដែន ព្រោះវាជាច្រកដែលអាចប្រព្រឹត្តបទល្មើសរត់ពន្ធទំនិញគ្រប់ប្រភេទដោយមិនមានបង់ពន្ធ ក៏ដូចជារត់ពន្ធមនុស្សជាដើម។ ឥឡូវមានការសំណូមពរពីប្រជាពលរដ្ឋដែលរស់នៅខេត្តជាប់ព្រំដែនថាឲ្យបើកច្រករបៀងឡើងវិញ ដើម្បីឲ្យពួកគាត់បានធ្វើការឆ្លងកាត់ចេញ-ចូល រកស៊ីលើទឹកដីថៃ ក្នុងការដោះស្រាយជីវភាពពីព្រោះពួកគាត់ចូលព្រឹក ត្រឡប់មកវិញពេលល្ងាច។

២.អំពីអាជ្ញាធរថៃ ចាប់បញ្ជូនពលករខ្មែរត្រឡប់មកវិញទាំងខុសច្បាប់ និងស្របច្បាប់ មានចំនួនពី១០០នាក់ទៅ២០០នាក់ក្នុង១ថ្ងៃ ស្ថិតក្នុងស្ថានភាពបែបនេះសូមឲ្យអាជ្ញាធរយើងរកវិធីដោះស្រាយឲ្យបានឆាប់រហ័ស ឲ្យថៃជួយផ្ដល់ព័ត៌មានដែលត្រូវបញ្ជូនពលករខ្មែរត្រឡប់មកវិញ បើយើងមិនដឹងមិនលឺ គេថារដ្ឋាភិបាលយើងមិនទទួលខុសត្រូវចំពោះពលរដ្ឋយើង ត្រូវបង្កលក្ខណៈងាយស្រួលដល់ពួកគាត់ ហើយអាជ្ញាធរយើងក៏ងាយស្រួលក្នុងការសាកសួរព័ត៌មានពីពួកគាត់ ហេតុអ្វីបានគាត់ទៅ? គាត់ទៅធ្វើការងារអ្វី? ម្យ៉ាងទៀតបើមានពលរដ្ឋខ្មែរណាម្នាក់មានគ្រោះថ្នាក់ ឬស្លាប់ អាជ្ញាធរយើងត្រូវធ្វើការស្រាវជ្រាវបន្ទាន់ឲ្យបានច្បាស់លាស់អំពីមូលហេតុដើម្បីដោះស្រាយជាមួយគ្រួសារគាត់នៅស្រុកកំណើត។

៣.យើងត្រូវធ្វើការរៀបចំឯកសារក្នុងការចុះ (MOU) ជាមួយបណ្ដាប្រទេសណាដែលមានពលរដ្ឋខ្មែរទៅធ្វើការ និងរស់នៅទីនោះ ដូចជាប្រទេសម៉ាឡេស៊ី យើងមិនទាន់បានធ្វើនៅឡើយទេ។ សម្ដេចបានបន្ថែមថា សូមឲ្យខាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ពន្លឿនពេលវេលា នៃការធ្វើឯកសារនានាក៏ដូចជាលិខិតឆ្លងដែនជូនប្រជាពលរដ្ឋ ជាពិសេសពលរដ្ឋខ្មែរដែលធ្វើការនៅប្រទេសថៃ។ សម្ដេច សូមឲ្យឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ធ្វើការណែនាំដល់ខាងតុលាការពង្រឹងការកាត់ក្ដីបទល្មើសជួញដូរមនុស្សឲ្យបានតឹងរឹង ក៏ដូចជាបទល្មើសគ្រឿងញៀនដែលសព្វថ្ងៃរដ្ឋាភិបាលយើងកំពុងរួមគ្នាយកចិត្តទុកដាក់ទប់ស្កាត់ និងមានវិធានការធ្ងន់ធ្ងរចំពោះជនល្មើសដែលបានជួញដូរ និងប្រើប្រាស់។

ជាថ្មីម្ដងទៀត **សម្ដេចក្រឡាហោម** បានមានប្រសាសន៍ឯកភាពលើឯកសារគោល នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧-២០១៨ និងបានប្រកាសដាក់ឲ្យប្រើប្រាស់ឯកសារគោល ចាប់ពីពេលនេះតទៅ។ សម្ដេច សូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ ដែលមានវត្តមាននៅក្នុងអង្គសិក្ខាសាលានាពេលនេះទទួលបានជោគជ័យគ្រប់ភារកិច្ច។

អង្គសិក្ខាសាលាបានបញ្ចប់នៅវេលាម៉ោង១០ និងសាមសិបនាទីព្រឹក ថ្ងៃខែឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ សីហា ឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

10/08/17

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍**

ជូ. ប៊ុនអេង

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែ សីហា ឆ្នាំ២០១៧

ប្រធានលេខាធិការដ្ឋាន

ឧត្តមសេនីយ៍ទោ [illegible]